រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

012KH01A-01

ក្រុមជំនុំតាមផ្ទះ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

១២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



គោលបំណង

ក្រុមជំនុំតាមផ្ទះមានតាំងពីសម័យកាលពួកសាវ័ក ។ លោកប៉ូលបានផ្តាំផ្ញើពាក្យសួរសុខទុក្ខដល់ក្រុមជំនុំ ដែលជួបជុំគ្នានៅផ្ទះរបស់នាងព្រីស្កា និងលោកអាគីឡាស ។ នៅសម័យកាលយើងសព្វថ្ងៃនេះ ដែលមានអាគារធំៗ និងវិហារធំល្វឹងល្វើយ ក៏នៅតែត្រូវការក្រុមជំនុំតាមផ្ទះជាចាំបាច់ដែរ ។ នៅតាមតំបន់ជាច្រើនក្រុមជំនុំតាមផ្ទះមានប្រសិទ្ធិភាពណាស់ ក្នុងការបង្កើតក្រុមជំនុំថ្មីៗបន្តទៀត ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

គេត្រូវការក្រុមជំនុំតាមផ្ទះថ្មី នៅកន្លែង :

- ដែលមានក្រុមជំនុំថ្មីៗបង្កើនចំនួនជាបន្ត ហើយត្រូវការរបៀបថ្វាយបង្គំ ដែលអ្នកជីកនាំថ្មីរបស់ក្រុមជំនុំទាំងនោះដែលមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ អាចរៀបចំ និងបង្រៀនទៅអ្នកឯទៀតបាន ។
- ដែលអាជ្ញាធរក្នុងស្រុក ហាមឃាត់មិនអោយមានការជួបជុំគ្នាថ្វាយបង្គំជាសាធារណៈ (មនុស្សក្នុងពិភពលោកចំនួនពាក់កណ្តាលរស់នៅតាមទីកន្លែងបែបនេះ ។ ហេតុនេះគ្រីស្តទូតត្រូវមានបទពិសោធន៍ខ្លាំងអំពីការបង្កើត និងការធ្វើអោយក្រុមជំនុំតាមផ្ទះរីកចំរើនឡើង) ។
- ដែលក្រុមជំនុំថ្មីពេក ឬ តូចពេក មិនត្រូវការអាគារព្រះ-វិហារទេ ។
- ដែលក្រុមជំនុំមិនទាន់អាចរកអាគារ ឬ ព្រះវិហារបាន ។
- ដែលដី និងការសាងសង់មានតំលៃខ្ពស់ពេក ។
- ដែលមានក្រុមជំនុំស្រាប់ហើយ តែក្រុមជំនុំទាំងនោះ គ្មានប្រសិទ្ធិភាពក្នុងការផ្សព្វផ្សាយដំណឹងល្អនៅតំបន់របស់គេ ។

© Project WorldReach © SEAN

- ដែលយើងជាគ្រីស្តជនមានបំណងចង់ថ្វាយបង្គំ តាមរបៀបប្រកបគ្នាជិតស្និទ្ធនៅតាមផ្ទះ ដូចក្រុមជំនុំដំបូង (កិច្ចការ ៥:៤២, ២០:២០, រ៉ូម ១៦:៥) ។

ពេលចាប់ផ្តើមធ្វើការថ្វាយបង្គំ កំហុសធម្មតារបស់ក្រុមជំនុំថ្មីៗនៅតាមផ្ទះ គឺធ្វើការថ្វាយបង្គំតាមរបៀបក្រុមជំនុំធំៗ ។ ក្រុមជំនុំធំៗធ្វើការថ្វាយបង្គំ ដោយមានតន្ត្រីករ ដែលបានហាត់រៀនត្រឹមត្រូវ មានអ្នកដឹកនាំដែលមានបទពិសោធន៍ និងមានមនុស្សជាច្រើនចូលរួមផង ។ ប៉ុន្តែ ក្រុមជំនុំតូចៗភាគច្រើន មិនអាចមានលទ្ធភាពធ្វើដូចនេះបានទេ ។

កិច្ចការដែលត្រូវអនុវត្ត

- សូមអាន អេភេសូ ៤:៧-១៦ ។
- សូមសរសេរពីផែនការរបស់អ្នក សំរាប់ជួយសមាជិកនៃក្រុមជំនុំ ឬ ក្រុមរបស់អ្នក អោយអាចចូលរួមក្នុងផ្នែកខ្លះនៃការថ្វាយបង្គំ និង បំពេញកិច្ចការបំរើផ្សេងទៀតបាន ។

© Project WorldReach © SEAN

មេរៀន ទី ១

បើក្រុមជំនុំអ្នកតូច មិនត្រូវធ្វើតាមរបៀបថ្វាយបង្គំរបស់ក្រុមជំនុំធំៗទេ !



- ☐ មិនសូវយកចិត្តទុកដាក់ចំពោះកុមារ និងយុវជន ។ ក្រុមជំនុំតាមផ្ទះត្រូវបង្ហាញសេចក្តីស្រឡាញ់ដល់កុមារ និងយុវជន និងជួយពួកគេឱ្យចូលរួមចំណែកក្នុងការថ្វាយបង្គំ ។ បើសិនជាក្រុមជំនុំរៀបចំអោយមានកន្លែងពិសេសមួយ ដើម្បីអោយកុមារមានថ្នាក់រៀនព្រះគម្ពីរ នោះជាការល្អ ។
- ☐ ខ្វះការបង្កើតសាវ័ក ។ ម្នាក់ៗ រួមទាំងកុមារផង សុទ្ធតែត្រូវការអ្នកបង្កើតសាវ័ក ដើម្បីណែនាំពួកគេអំពីព្រះបន្ទូលព្រះជាម្ចាស់ ។ កិច្ចការបំរើនេះ ត្រូវប្រគល់អោយមនុស្សដែលចាស់ទុំខាងជំនឿ និងដែលមានអំណោយទានខាងការបង្កើតសាវ័ក ។ ឧទាហរណ៍ អ្នកដឹកនាំបង្រៀនអ្នកជំនួយ និងអ្នកដែលចាស់ទុំខាងព្រលឹងវិញ្ញាណឯទៀតនៅក្នុងក្រុម អោយក្លាយជាសាវ័ក ហើយពួកអ្នកទាំងនេះ នឹងបង្រៀនអ្នកផ្សេងទៀតអោយក្លាយជាសាវ័កដែរ ។ គោលដៅ គឺត្រូវជួយសមាជិកទាំងអស់ ទាំងចាស់ទាំងក្មេង ឱ្យប្រតិបត្តិតាមព្រះជាម្ចាស់ អោយរីកចំរើនឡើង និងធ្វើកិច្ចការបំរើរបស់គេផ្ទាល់ ។

ពេលមនុស្សដើរចូលទៅក្នុងព្រះវិហារ ពួកគេទាំងនោះដឹងច្បាស់ថា ព្រះវិហារជាទីកន្លែងសំរាប់ថ្វាយបង្គំ ។ ប៉ុន្តែ នៅក្នុងក្រុមជំនុំតាមផ្ទះវិញ គេឮសូរក្មេងកំពុងលេងនៅក្នុងបន្ទប់ ឃើញឆ្កែកំពុងអង្គុយអេះនៅកៀនជញ្ជាំង ហើយធំក្លិនម្ហូបអាហារនៅផ្ទះបាយ ដែលធ្វើអោយគេពិបាកចាត់ទុកផ្ទះនោះ ជាកន្លែងបរិសុទ្ធសំរាប់ថ្វាយបង្គំណាស់ ។

មេរៀន ទី ២

យើងត្រូវធ្វើអោយការថ្វាយបង្គំតាមផ្ទះមានប្រសិទ្ធិភាព ។

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាលនេះ នឹងជួយក្រុមគួចអោយអាចធ្វើការថ្វាយបង្គំ ដែលកសាងសមាជិកក្រុមគួច ព្រមទាំងជួយអ្នកដឹកនាំថ្មីៗអោយចេះរៀបចំការថ្វាយបង្គំ ដែលមានប្រសិទ្ធិភាពនៅក្នុងក្រុមជំនុំតាមផ្ទះ ។



ដែលមិនទាន់បានសង្គ្រោះ និងចេះបំពេញភារៈកិច្ចខាងសង្គម ដោយហ្មត់ចត់នៅក្នុងសង្កាត់នោះ ។

- ☐ គ្រូគង្វាលគ្រប់គ្រងលើអ្វីៗទាំងអស់ ។ ក្រុមជំនុំតាមផ្ទះជាច្រើនត្រូវបានលិចលង់ ដោយសារតែអ្នកដឹកនាំមិនបានណែនាំអ្នកឯទៀតអោយចេះទទួលខុសត្រូវ ឬ ជួយដឹកនាំកម្មវិធីថ្វាយបង្គំ ។ សមាជិកម្នាក់ៗនៃព្រះកាយ (ក្រុមជំនុំ) ទទួលអំណោយទានខាងព្រលឹងវិញ្ញាណពីព្រះជាម្ចាស់សំរាប់ធ្វើកិច្ចការបំរើខ្លះ ហើយគេត្រូវតែប្រើអំណោយទានទាំងនោះ (រ៉ូម ១២:៤-១៦) ។
- ☐ នៅពេលដែលសមាជិកឃើញមានចំនួនមនុស្សកើនឡើង គេក៏ឈប់ទទួលខុសត្រូវផ្ទាល់ ហើយក្លាយទៅជាអ្នកដែលចាំតែអង្គុយមើល ហើយទុកអោយគ្រូគង្វាល និងអ្នកចាស់ទុំធ្វើកិច្ចការទាំងអស់នោះ ។ ត្រូវលើកទឹកចិត្តសមាជិកទាំងអស់អោយបន្តរីកចំរើនក្នុងការងារបំរើរបស់គេផ្ទាល់ ហើយអ្នកដឹកនាំខ្លួនឯងត្រូវធ្វើជាគំរូដល់គេ ។ បើអ្នកដឹកនាំថ្មីធ្វើដូចនេះ គាត់នឹងអាចមើលឃើញសមាជិក ដែលអាចបង្កើតក្រុមជំនុំសាខាបន្តយ៉ាងឆាប់រហ័ស ។

© Project WorldReach © SEAN

□ ខ្វះអ្នកដឹកនាំដែលមានសមត្ថភាព និង បទពិសោធន៍ ។ អ្នកដឹកនាំរបស់ក្រុមជំនុំតាមផ្ទះនិមួយៗ ត្រូវតែត្រៀមអ្នកដឹកនាំជំនួយអោយបានពីរ ឬ បីនាក់ ។ អ្នកដឹកនាំជំនួយទាំងអស់នោះត្រូវមានការទទួលខុសត្រូវកាន់តែច្រើនបន្តិចម្តងៗ រហូតដល់គេអាចឃ្វាលក្រុមជំនុំតាមផ្ទះដោយខ្លួនគេបាន ។ បន្ទាប់មក គេបង្កើតក្រុមរបស់គេផ្ទាល់ ឬបន្តធ្វើជាគ្រូគង្វាលជំនួយ (ចាស់ទុំ)របស់ក្រុមជំនុំដើមនោះ ។

□ អ្នកដឹកនាំគ្រាន់តែជួយដោះស្រាយសេចក្តីត្រូវការរបស់សមាជិក តែមិនណែនាំពួកសមាជិកអោយធ្វើកិច្ចការបំរើដល់អ្នកដទៃ ។ ក្រុមជំនុំតាមផ្ទះខ្លះ ក្លាយជាក្រុមជំនុំដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ។ ក្រុមជំនុំបែបនោះ មិនរីកចំរើនឡើង និងមិនបង្កើនចំនួនបន្តទេ ដោយសារគេបំពេញតែសេចក្តីត្រូវការរបស់ខ្លួនឯងប៉ុណ្ណោះ គឺមិនចេញទៅបំរើដល់សហគមន៍ដែលនៅជុំវិញខ្លួន ទៅតាមរបៀបដែលមានប្រយោជន៍សំរាប់ប្រជាជនដែលរស់នៅក្នុងសង្គមនោះទេ ។ បទគម្ពីរអេភេសូ ៤:១១-១៦ ចែងច្បាប់គ្រីស្តបរិស័ទអោយបំរើមនុស្សឯទៀតទៅតាមមុខងារ ដែលព្រះវិញ្ញាណបានប្រទានឱ្យពួកគេ ។ ត្រូវរៀបចំសមាជិកឱ្យចេះបំរើមនុស្ស

កន្លែងថ្វាយបង្គំនៅតាមផ្ទះ

តើយើងត្រូវរៀបចំបន្ទប់នៅតាមផ្ទះ អោយទៅជាកន្លែងសំរាប់អធិស្ឋាន និង ថ្វាយបង្គំដោយរបៀបណា ?

គ្មានរបៀបកំណត់សំរាប់រៀបចំ ឬ តុបតែងបន្ទប់អោយក្លាយជាកន្លែងសំរាប់ថ្វាយបង្គំនោះទេ ។ ការរៀបចំផ្ទះ ដើម្បីធ្វើជាកន្លែងថ្វាយបង្គំអាស្រ័យលើទំនៀមទំលាប់របស់តំបន់នោះ និង សំភារៈដែលអាចរកបាន ។ គ្រីស្តបរិស័ទខ្លះ ចូលចិត្តអង្គុយជារង្វង់មូល ខ្លះទៀតនិយមរៀបចំតាមរបៀបសាមញ្ញ ខ្លះទៀតចូលចិត្តរៀបចំបន្ទប់ឱ្យបានពិសេស ។ សេចក្តីសំខាន់បំផុតនោះ គឺទឹកចិត្ត និងជំនឿរបស់យើង មិនមែនបន្ទប់ ឬ ទីកន្លែងនោះឡើយ ។

អ្នកអាចរៀបចំផ្ទះសំរាប់ធ្វើជាកន្លែងថ្វាយបង្គំ តាមជំហានខាងក្រោមនេះ :

- ជ្រើសរើសបន្ទប់ដែលមានភាពស្ងៀមសាត់ គ្មានការរំខានតាមដែលអាចធ្វើបាន ។
- ក្រាលកន្ទេលតាមរបៀប ដែលអោយមនុស្សអាចអង្គុយជារង្វង់មូល ។

- នៅកណ្តាលរង្វង់ ត្រូវដាក់នំប៉័ង និងទឹកទំពាំងបាយជូរ ឬ របស់អ្វីផ្សេងទៀត ដែលចាំបាច់សំរាប់ធ្វើពិធីកាច់នំប៉័ង ។
- មនុស្សខ្លះព្យួរផ្ទាំងក្រដាស ឬ ក្រណាត់ដែលមានសរសេរខ ព្រះគម្ពីរ ឬ មានរូបភាពជានិមិត្តរូបនៅលើជញ្ជាំង ដើម្បី បង្ហាញថាការថ្វាយបង្គំចាប់ផ្តើមហើយ ។

តើកន្លែងណាដែលល្អបំផុត សំរាប់ឱ្យក្រុមរបស់អ្នកជួបជុំគ្នាបាន ?

_____

_____

ស្មមរៀបរាប់ដោយសង្ខេប ពីរបៀបដែលអ្នកនឹងរៀបចំបន្ទប់ ដើម្បីថ្វាយបង្គំ ។

_____

_____

_____

_____

_____

_____

☐ ក្រុមជំនុំមានគ្នាច្រើនមិនអាចជួបជុំគ្នានៅផ្ទះបាន ។ នៅតាមផ្ទះ បើសិនជាបន្ទប់ចង្អៀតពេក មិនអាចដាក់មនុស្សដែលចូលរួមជាទៀងទាត់បាន ពួកគេអាចជ្រើសរើសរកសាលប្រជុំធំជាងនេះ និងក្លាយទៅជាព្រះវិហារដែលពេញលក្ខណៈ ឬបែងចែកជាពីរក្រុមដោយបង្កើតជាក្រុមថ្មីតាមផ្ទះមួយទៀត ។ អ្នកត្រូវមានផែនការសំរាប់ពេលអនាគតដោយរៀបចំអោយមានអ្នកជំនួយ ដែលអាចបង្កើតក្រុមរបស់គេផ្ទាល់ នៅពេលក្រោយទៀតបាន ។

☐ ការរំខាននៅពេលថ្វាយបង្គំ ។ សមាជិកក្នុងក្រុមជំនុំត្រូវមានវេនសំរាប់ទទួលខុសត្រូវថែរក្សាកុមារ និងទទួលភ្ញៀវតាមផ្ទះ ។

☐ ក្រុមជំនុំតាមផ្ទះជាច្រើនមិនបង្កើតផលផ្លែ ដោយសារតែគេធ្វើតាមរបៀបថ្វាយបង្គំរបស់ក្រុមជំនុំដើម(ធំ) ។ របៀបថ្វាយបង្គំរបស់ក្រុមជំនុំដើម អាចមានលទ្ធផលល្អនៅក្នុងក្រុមជំនុំដើមនោះ ។ ប៉ុន្តែ របៀបនោះមិនសមស្របសំរាប់ក្រុមជំនុំថ្មីតាមផ្ទះទេ ។ យើងត្រូវតម្រូវរបៀបថ្វាយបង្គំអោយត្រូវតាមក្រុមតូច ដែលមានអ្នកដឹកនាំគ្មានបទពិសោធន៍ ។

© Project WorldReach © SEAN

□ មិនស្ថិតមានទំនាក់ទំនងជាមួយក្រុមជំនុំឯទៀត ។ ឃ្លាំងក្រុមជំនុំតូចតាមផ្ទះ ត្រូវតែជួបជាមួយនឹងក្រុមជំនុំតាមផ្ទះឯទៀត ដើម្បីធ្វើពិធីធំមួយពេញដោយអំណរ ។ បើសិនជារដ្ឋអំណាចហាមឃាត់ មិនអោយធ្វើពិធីដូចនេះ នោះត្រូវឱ្យគ្រីស្តជនខ្លះនាំយកដំណឹង និងពាក្យលើកទឹកចិត្តទៅសួរសុខទុក្ខក្រុមជំនុំតាមផ្ទះឯទៀត ។ អ្នកអាចផ្ញើព្រឹត្តប័ត្រពត៌មានមួយទៅតាមក្រុមជំនុំតាមផ្ទះផ្សេងៗទៀត ។ ការសំខាន់គឺត្រូវបង្កើតបណ្តាញក្រុមជំនុំតាមផ្ទះ ដែលគាំទ្រគ្នាទៅវិញទៅមក ។

□ ក្រុមជំនុំច្រើនតែជួបជុំគ្នានៅក្នុងផ្ទះរបស់អ្នកដឹកនាំ ។ តាមធម្មតា បើកុំជួបជុំគ្នានៅផ្ទះរបស់អ្នកដឹកនាំ ទើបប្រសើរ ។ ព្រោះនាំអោយអាចចៀសវាងពាក្យរិះគន់ថា អ្នកដឹកនាំកាន់កាប់ក្រុមជំនុំនេះ ធ្វើជារបស់គាត់"ផ្ទាល់" ។ សមាជិកក៏មានការស្ទាក់ស្ទើរមិនសូវហ៊ានផ្តល់គំនិតយោបល់របស់គេនៅក្នុងក្រុមជំនុំ ដែលជួបជុំគ្នានៅតាមផ្ទះរបស់អ្នកដឹកនាំដែរ ។

ផ្នែកសំខាន់ៗក្រាំបីនៃការថ្វាយបង្គំក្នុងក្រុមជំនុំតាមផ្ទះ

ទោះជាទីកន្លែងមានសភាពសាមញ្ញ និងសមាជិកមានចំនួនតិចក៏ដោយ ក៏អ្នកដឹកនាំក្រុមតូចតាមផ្ទះមិនត្រូវយល់ច្រឡំថា មិនបាច់រៀបចំពិធីថ្វាយបង្គំអោយបានត្រឹមត្រូវ និងអស់ពីចិត្តនោះដែរ ។ ផ្ទុយទៅវិញ ដោយសារបរិយាកាសនៅក្រុមជំនុំតាមផ្ទះ អាចនាំឱ្យមនុស្សបែកអារម្មណ៍ នោះអ្នកដឹកនាំក្រុមជំនុំតាមផ្ទះត្រូវតែរៀបចំការថ្វាយបង្គំអោយបានល្អ ដើម្បីឱ្យពួកអ្នកចូលរួម អាចថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា ដោយមានន័យ ។



អ្នកដឹកនាំត្រូវចៀសវាងការរៀបចំធ្វើការថ្វាយបង្គំដែលយូរ និងដែលគួរអោយធុញទ្រាន់ ព្រោះអាចនាំអោយអ្នកចូលរួម ពិសេសយុវជន បែកចេញពីក្រុមជំនុំ ។

សូមប្រើផ្នែកទាំងប្រាំបីនៃការថ្វាយបង្គំនេះជាបន្តបន្ទាប់តាមលំដាប់លំដោយ ដែលត្រូវសំរាប់ក្រុមរបស់អ្នក ។ ចំណុចទាំងនេះ មិនមែនជារបៀបវារៈនៃការថ្វាយបង្គំទេ តែជាផ្នែកធម្មតានៃការថ្វាយបង្គំ (យើងនឹងដាក់ជូនរបៀបវារៈនៃការថ្វាយបង្គំ នៅទំព័រក្រោយៗទៀត នៅក្នុងមេរៀននេះ) ។

ផ្នែកសំខាន់ៗនៃការថ្វាយបង្គំ :

- ត្រូវឱ្យមានការចាប់ផ្តើម និងការបញ្ចប់នៃការប្រជុំថ្វាយបង្គំច្បាស់លាស់ ។
- ការលន់តួសារភាពអំពើបាប និងការបញ្ជាក់ពីការដែលព្រះជាម្ចាស់បានលើកលែងទោសអំពើបាប ។ (ជាធម្មតាយើងធ្វើកិច្ចការនេះ មុនធ្វើពិធីកាច់នំបុ័ង) ។
- ការច្រៀងសរសើរតម្កើងព្រះជាម្ចាស់ ។
- ការធ្វើទីបន្ទាល់ ។
- ការធិស្ឋាន ។
- ការដាក់ប្រាក់ដង្វាយ ។

មូលហេតុដែលធ្វើអោយក្រុមជំនុំតាមផ្ទះមិនទទួលបានលទ្ធផលល្អ

សូមគូសសញ្ញា «✓» នេះ នៅនឹងកំហុសដែលអ្នកត្រូវកែតម្រូវក្នុងក្រុមជំនុំរបស់អ្នក :

☐ ម្ចាស់ផ្ទះមានអារម្មណ៍ថា ខ្លួនត្រូវធ្វើការរៀបចំយ៉ាងច្រើន ។ ដើម្បីចៀសវាងការខ្វល់ខ្វាយនេះ សូមកុំរៀបចំអ្នបអាហារដើម្បីទទួលភ្ញៀវឡើយ (លើកលែងតែក្នុងឱកាសពិសេស)។

☐ មនុស្សដែលមានគោលដៅផ្សេង ខុសពីគោលបំណងរបស់ក្រុមជំនុំ ផ្សព្វផ្សាយពីចំណូលចិត្តរបស់គេផ្ទាល់ ។ មិនត្រូវអោយនរណាម្នាក់ឆ្លៀតធ្វើជំនួញ ឬនិយាយពីនយោបាយនៅពេលប្រជុំគ្នាទេ ។

☐ ក្រុមជំនុំច្រើនតែឈប់ផ្សព្វផ្សាយដំណឹងល្អ នៅពេលដែលក្រុមជំនុំនោះចាប់ផ្តើមមានកម្មវិធីថ្វាយបង្គំ ។ ត្រូវបន្តស្វែងរកចៀមដែលបាត់បង់ ទើបត្រឹមត្រូវ ។

☐ ភរិយា ឬ ស្វាមីរបស់អ្នកដឹកនាំ មិនគាំទ្រកិច្ចការបំរើរបស់គាត់ ។ ការនេះធ្វើអោយមានភាពតឹងតែងនៅក្នុងគ្រួសារ និងក្នុងក្រុមជំនុំ ។

ចំលើយ :

- ត្រូវអោយមានការចាប់ផ្តើម និង ការបញ្ចប់ការប្រជុំថ្វាយ-បង្គំច្បាស់លាស់ ។
- ការលន់តួសារភាពអំពើបាប និង ការបញ្ជាក់ពីការដែលព្រះជាម្ចាស់បានលើកលែងទោសអំពើបាប ។
- ការសរសើរតម្កើងព្រះជាម្ចាស់ ។
- ទីបន្ទាល់ ។
- ការធិស្ឋាន ។
- ការដាក់ប្រាក់ដង្វាយ ។
- សិក្សា និងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។
- ធ្វើពិធីកាច់នំប៉័ង ។ (បើមិនបានធ្វើប្រចាំសប្តាហ៍ទេ សូមកំណត់ពេលធ្វើអោយបានទៀងទាត់) ។

តើផ្នែកណាមួយដែលអ្នកត្រូវសិក្សាថែមទៀត ដើម្បីអោយអ្នកអាចអនុវត្តបានកាន់តែល្អប្រសើរឡើង ?

- ការសិក្សា និងអនុវត្តន៍តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។
- ការធ្វើពិធីកាច់នំប៉័ង ។ (បើមិនបានធ្វើប្រចាំសប្តាហ៍ទេ សូមកំណត់ពេលធ្វើអោយបានទៀងទាត់) ។

កំណត់សំគាល់ :
ការរៀបចំកំណត់ពេលវេលាសំរាប់ការបង្កើតសាវ័ក និងការប្រកបគ្នា (ដែលជាឱកាសសំរាប់សួរសុខទុក្ខគ្នាទៅវិញទៅមក) ក៏ជាការសំខាន់ណាស់ដែរ ។

ត្រូវអោយមានការចាប់ផ្តើម និង ការបញ្ចប់នៃការប្រជុំថ្វាយបង្គំច្បាស់លាស់

ដោយសារមជ្ឈដ្ឋានដែលនៅជុំវិញ មានលក្ខណៈសាមញ្ញ ការចាប់ផ្តើម និងការបញ្ចប់ការថ្វាយបង្គំ នៅក្រុមតូចតាមផ្ទះត្រូវតែច្បាស់លាស់ ។

គំរូនៃការបើកការថ្វាយបង្គំ (ការចាប់ផ្តើម) :

- ទាំងអស់គ្នាក្រោកឈរឡើង ។

- អ្នកដឹកនាំលើកទឹកចិត្តមនុស្សទាំងអស់ ឱ្យថ្វាយបង្គំដោយអានខគម្ពីរទំនុកតម្កើង ឬខគម្ពីរផ្សេងទៀត ដែលធ្វើអោយគេអាចផ្ចង់អារម្មណ៍ទៅរកព្រះជាម្ចាស់ ។

- អ្នកដឹកនាំ ឬអ្នកណាម្នាក់ដែលគាត់ចាត់តាំង អធិស្ឋានទូលសូមអោយព្រះជាម្ចាស់យាងមកគង់កណ្តាលចំណោមពួកគេ និង នាំពួកគេអោយដឹងពីវត្តមានរបស់ព្រះអង្គ ដូចដែលមានចែងក្នុងហាបាគូក ២:២០ *«ព្រះអម្ចាស់គង់នៅក្នុងព្រះវិហារដ៏វិសុទ្ធរបស់ព្រះអង្គ ចូរអោយផែនដីទាំងមូលសៀមសាត់នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ »* ។

សកម្មភាពបើកការថ្វាយបង្គំត្រូវខ្លី តែឧឡារឹក និងនាំមនុស្សឱ្យផ្ចង់ចិត្តគំនិតទៅរកព្រះជាម្ចាស់ពិត ។ ការចាប់ផ្តើម ត្រូវធ្វើឱ្យយើងដឹងថា យើងកំពុងឈានចូលជាក្រុម ក្នុងវត្តមានដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងទាំងអស់គ្នាទប់អារម្មណ៍ ហើយគិតតែពីព្រះជាម្ចាស់ ។

ចំលើយ :

១ = ការបើកការថ្វាយបង្គំ ។ ២ = ការសរសើរតម្កើង ។

៣ = គំរូអំពីរបៀបអធិស្ឋាន ។ ៤ = ការលន់តួសារភាព ។

៥ = ការបង្រៀន និង ការអនុវត្តតាមព្រះបន្ទូល ។

៦ = ពិធីកាច់នំប៉័ង ។ ៧= ដាក់ដង្វាយ ។

៨ = ការបង្កើតសាវ័ក និង ការប្រកបគ្នា ។

៩- តើអ្នកមានរំលឹកឡើងវិញពីផ្នែកសំខាន់ទាំងប្រាំបីនៃការថ្វាយបង្គំដែរឬទេ ? សូមសរសេរផ្នែកទាំងប្រាំបី តាមការចងចាំ មុននឹងពិនិត្យមើលចំលើយខាងក្រោមនេះ ។

© Project WorldReach © SEAN

៧- យើងអធិស្ឋានថ្វាយប្រាក់ដង្វាយដល់ព្រះជាម្ចាស់ នៅពេល :

- ☐ លន់តួសារភាពបាប ។
- ☐ សរសើរតម្កើង ។
- ☐ ដាក់ដង្វាយ ។
- ☐ បង្កើតសាវ័ក និង ប្រកបគ្នា ។

៨- នៅមុន ឬ ក្រោយការថ្វាយបង្គំ ត្រូវមានពេលសំរាប់ :

- ☐ ការលន់តួសារភាពបាប ។
- ☐ ពិធីកាច់នំប៉័ង ។
- ☐ ការបង្រៀនព្រះបន្ទូល ។
- ☐ ការបង្កើតសាវ័ក និង ការប្រកបគ្នា ។

គំរូនៃការបិទការថ្វាយបង្គំ (ការបញ្ចប់) :

- ទាំងអស់គ្នាក្រោកឈរឡើង ។
- ច្រៀងចំរៀងពិសេសមួយបទ ។
- អ្នកដឹកនាំអធិស្ឋានពិសេសសំរាប់បិទការប្រជុំថ្វាយបង្គំ ។
- អញ្ជើញអ្នកចូលរួមអោយសួរសុខទុក្ខគ្នាទៅវិញទៅមក មុននឹងត្រឡប់ទៅផ្ទះវិញ ។
- ដកក្រដាស ឬ ក្រណាត់ដែលមានសរសេរខព្រះគម្ពីរ ឬ មានរូបភាពជានិមិត្តរូបចេញពីជញ្ជាំង (បើសិនជាមានព្យួរលើជញ្ជាំង) ។



ខគម្ពីរខ្លះសំរាប់បើកការថ្វាយបង្គំ (ជំរុញទឹកចិត្តគេអោយថ្វាយបង្គំ) :

កំណើត. ២៨:១៦-១៧
ទំនុកតម្កើង ២៧:៤
ទំនុកតម្កើង ៤៣:៣-៤
ទំនុកតម្កើង ១០០:១-២
ទំនុកតម្កើង ១១៨:២៤
ទំនុកតម្កើង ១៣៦:១
ទំនុកតម្កើង ១៥០:១-២
សំណោក ៣:២៥-២៦
ហាបាគូក ២:២០
វិវរណៈ ៣:២០
វិវរណៈ ១៥:៤

ទុតិយកថា ៦:៤-៥
ទំនុកតម្កើង ២៨:៦-៧
ទំនុកតម្កើង ៦៦:១-២
ទំនុកតម្កើង ១១៥:១
ទំនុកតម្កើង ១២២:១
ទំនុកតម្កើង ១៤៧:១-២
អេសាយ ៦:៣
សំណោក ៣:៤០-៤១
ម៉ាថាយ ១១:២៨
វិវរណៈ ៤:១១

៥- តើការពន្យល់វគ្គព្រះគម្ពីរ ទាក់ទងខ្លាំងជាងគេទៅនឹងផ្នែកណាមួយនៃការថ្វាយបង្គំ ?

- ☐ ការបើកការថ្វាយបង្គំ ។
- ☐ ការលន់តួសារភាព ។
- ☐ ការបង្រៀន និងការអនុវត្តតាមព្រះបន្ទូល ។
- ☐ ពិធីកាច់នំប៉័ង ។
- ☐ ការដាក់ដង្វាយ ។

៦- *«សូមទទួល ហើយបរិភោគចុះ ។ នេះជារូបកាយខ្ញុំ»* ជាផ្នែកនៃ :

- ☐ ការបង្កើតសាវ័ក និង ការប្រកបគ្នា ។
- ☐ ការសរសើរតម្កើង ។
- ☐ ការអធិស្ឋាន ។
- ☐ ពិធីកាច់នំប៉័ង ។

© Project WorldReach © SEAN

៣- «ព្រះវរបិតាដែលគង់នៅស្ថានសួគ៌... » ទាក់ទងខ្លាំងជាង ទៅនឹង :

- ☐ ការបង្កើតសាវ័ក និងការប្រកបគ្នា ។
- ☐ ការសរសើរតម្កើង ។
- ☐ គំរូអំពីរបៀបដែលត្រូវអធិស្ឋាន ។
- ☐ ការបង្រៀនព្រះបន្ទូល ។
- ☐ ពិធីកាច់នំប៉័ង ។

៤- ទូលបង្គំទទួលសារភាពថា ទូលបង្គំបានធ្វើខុសហើយ (ទំនុកតម្កើង ៥១) សំរាប់ :

- ☐ ការបើកការថ្វាយបង្គំ ។
- ☐ ការលន់តួសារភាព ។
- ☐ ការបង្រៀនព្រះបន្ទូល ។
- ☐ ពិធីកាច់នំប៉័ង ។

ខគម្ពីរខ្លះសំរាប់បើកការថ្វាយបង្គំពិសេស :

បុណ្យថ្ងៃកំណើតរបស់ព្រះយេស៊ូ

អេសាយ ៩:៦	អេសាយ ៤០:១-២
អេសាយ ៤០:៣-៤	អេសាយ ៤០:៥
អេសាយ ៥២:៧-៨	អេសាយ ៦០:១-២
សាការី ២:១០	លូកា ២:១០-១១

បុណ្យរំឭកការសុគតរបស់ព្រះយេស៊ូ

ទំនុកតម្កើង ១៦:១០-១១	សាការី ១២:១០
លូកា ២៤:៤៥-៤៦	អេភេសូ ៦:៦-៧
ហេប្រឺ ៤:១៤	ហេប្រឺ ៤:១៥-១៦
ហេប្រឺ ១០:១៩-២២	សាការី ៩:៩
ទំនុកតម្កើង ២៤:៧	ទំនុកតម្កើង ១១៨:២៦
អេសាយ ៥៣:៥	អេសាយ ៥៣:៦
អេសាយ ៥៣:៧	

បុណ្យរំពួកថ្ងៃ ដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

ម៉ាថាយ ២៨:៥-៦ | កិច្ចការ ១៣:៣២-៣៣
១ ក្ងរិនថូស ១៥:១៥-២០ | ១ ពេត្រុស ១:៣

បុណ្យថ្ងៃទីហាសិប

យ៉ូអែល ២:២៨-២៩
យ៉ូហាន ៤:១៣-១៥
យ៉ូហាន ៤:២៣-២៤

បុណ្យចូលឆ្នាំថ្មី ឬ បុណ្យភ្ជំបិណ្ឌ

ទំនុកតម្កើង ៤០:១-៦ | ទំនុកតម្កើង ៦៧:៦-៧
ទំនុកតម្កើង ១២៦:៥-៦ | ម៉ាកុស ៤:១-២០

ការរំពួកគុណគ្រូ

ហេប្រឺ ១៣:៧ | ១ ថេស្សាឡូនិក ៥:១២-១៣
កាឡាទី ៦:៦ | ១ ក្ងរិនថូស ៩:៧-១០

ការប្រឡង (សំនួរសង្ខេបមេរៀន)

លំហាត់នេះ ជួយអ្នកឱ្យមានគំនិតអំពីផ្នែកសំខាន់ៗនៃការថ្វាយបង្គំ និង គោលបំណងរបស់ផ្នែកទាំងនោះ ។ គូសសញ្ញា «✓» នេះ នៅនឹងចំលើយដែលត្រឹមត្រូវ ។

១- ចូរចូលតាមទ្វារព្រះដំណាក់របស់ព្រះអង្គ ដោយច្រៀង ។ ចូរនាំគ្នា ចូលមកក្នុងព្រះវិហារ ដោយពាក្យសរសើរតម្កើង (ទំនុកតម្កើង ១០០:៤) សមរម្យសំរាប់ :

- ☐ ការបើកការថ្វាយបង្គំ ។
- ☐ ការអធិស្ឋាន ។
- ☐ ការបង្រៀនព្រះបន្ទូល ។
- ☐ ពិធីកាច់នំបុ័ង ។

២- ខ្ញុំសូមសរសើរតម្កើងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គអស់ពីដួងចិត្ត (ទំនុកតម្កើង ១០៣) ទាក់ទងខ្លាំងជាងគេទៅនឹង :

- ☐ ការបង្កើតសាវ៉ក និងការប្រកបគ្នា ។
- ☐ ការសរសើរតម្កើង ។
- ☐ ការអធិស្ឋាន ។
- ☐ ការបង្រៀនព្រះបន្ទូល ។
- ☐ ការធ្វើពិធីកាច់នំបុ័ង ។

(បន្ទាប់មក) **ការបង្កើតសាវ័ក និង ការប្រកបគ្នា**

- របាយការណ៍ និងគំរោងផែនការអំពីកិច្ចការបំរើរបស់សមាជិក ។

បញ្ចប់កម្មវិធីនៅម៉ោងដែលសមរម្យសំរាប់មនុស្សគ្រប់គ្នា ។
រៀបចំបន្ទប់ឡើងវិញ និងអរគុណដល់ម្ចាស់ផ្ទះ ។



ការរំឭកគុណម៉ែឪ

អេភេសូ ៦:១-៣
សុភាសិត ១:៨-១៩
១ ធីម៉ូថេ ៥:៤
សុភាសិត ១០:១

ខគម្ពីរខ្លះសំរាប់ការប្រជុំថ្វាយបង្គំ (ព្រះពរ) :

ជំរឿនប្រជាជន ៦:២៣-២៦
រ៉ូម ១៦:២០
១ ធីម៉ូថេ ១:២
រ៉ូម ១៥:៣៣
២ កូរិនថូស ១៣:១៤
ហេប្រឺ ១៣:២០-២១

© Project WorldReach © SEAN

ការលន់តួសារភាពអំពើបាប និងការបញ្ជាក់ពីការដែលព្រះជាម្ចាស់បានលើកលែងទោសអំពើបាប

សូម្បីតែគ្រីស្តបរិស័ទ ដែលព្រះជាម្ចាស់បានសង្គ្រោះអោយរួចពីអំពើបាបជារៀងរហូតហើយក៏ដោយ បើគេនៅតែប្រព្រឹត្តអំពើបាបទៀត គេត្រូវសារភាពអំពើបាបទាំងនោះ ដូចដែលព្រះជាម្ចាស់បានបង្គាប់យើងនៅក្នុង ១ យ៉ូហាន ១:៨-១០ដែរ ។ ការធ្វើដូចនេះ អាចសំរុះសំរួលយើងអោយជានានឹងព្រះអម្ចាស់ ដើម្បីអាចឈានទៅចូលរួមធ្វើពិធីកាច់នំប៉័ង ។

គំរូអំពីរបៀបលន់តួសារភាពអំពើបាបរបស់យើង :

- ការអធិស្ឋានលន់តួសារភាពក្នុងចិត្ត :
  ប្រវត្តិសាស្ត្របង្ហាញថា ត្រូគង្វាលភាគច្រើនដឹកនាំសមាជិករបស់ខ្លួនអោយនិយាយសារភាពអំពើបាបថា គេបានធ្វើខុសឆ្គងដែលនាំអោយអ្នកដទៃ និង ព្រះជាម្ចាស់ឈឺចាប់ ព្រមទាំងសារភាពថា ពួកគេមិនបានធ្វើកិច្ចការដែលគេត្រូវធ្វើដែរ ។

ការដាក់ដង្វាយ

- ទទួលដង្វាយស្ម័គ្រចិត្ត និងដង្វាយដប់ភាគរយ ។
- ការអធិស្ឋានថ្វាយដង្វាយស្ម័គ្រចិត្ត និងដង្វាយដប់ភាគរយថ្វាយព្រះជាម្ចាស់ ។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់

- អធិស្ឋានទូលសូមឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតយើងដើម្បីអោយយើងយល់ និងអនុវត្តតាមព្រះបន្ទូល ។
- ការអានខព្រះគម្ពីរ ដែលស្តីពីប្រធានបទសំរាប់ថ្ងៃនោះ ការពិភាក្សាគ្នា ការដាស់តឿន និងការរិះគិតពីអត្ថបទគម្ពីរដែលបានអាននោះ ។
- បទចំរៀងសរសើរតម្កើងដែលស្តីពីការប្តេជ្ញាចិត្ត និងដែលទាក់ទងទៅនឹងប្រធានបទសំរាប់ថៃនោះ (ឈរ) ។

ការចូលរួមធ្វើពិធីកាច់នំប៉័ង

- ការថ្វាយនំប៉័ង និងទឹកទំពាំងបាយជូរទៅព្រះជាម្ចាស់ ។
- ទទួលនំប៉័ង និងទឹកទំពាំងបាយជូរ ។
- ច្រៀងអរព្រះគុណ និងសរសើរតម្កើងដោយអំណរ ។
- ការអធិស្ឋានបិទការប្រជុំ (អធិស្ឋានខ្លី) ។

ការសរសើរតម្កើង

- បទចំរៀង និងការអានព្រះគម្ពីរសំរាប់ការសរសើរតម្កើង (ឈរ) ។
- ការអធិស្ឋាន និង ការបន្លឺសំលេង ដើម្បីសរសើរតម្កើងព្រះជាម្ចាស់ ។

ការធ្វើទីបន្ទាល់

- សូមប្រកាសជាមួយគ្នាអំពីគោលជំនឿរបស់ពួកសាវ័ក ឬ សេចក្តីផ្សេងទៀតដែលស្រដៀងគ្នា ដែលនិយាយអំពីជំនឿ (ឈរ) ។
- ធ្វើទីបន្ទាល់អំពីកិច្ចការដែលព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់គេ និង ក្រុមគ្រួសារ ។

ការអធិស្ឋាន

- អធិស្ឋានអោយអ្នកចូលរួម ប្រជាជាតិ ក្រុមជំនុំ អ្នកឈឺ ការផ្សព្វផ្សាយដំណឹងល្អនៅក្នុងពិភពលោក ។ល។ ។ (លុតជង្គង់ ឬ ឈរ) ។

- ការអានបទគម្ពីរអំពីការលន់តួសារភាពអំពើបាប : (ដូចជាទំនុកតម្កើង ៥១, ១ យ៉ូហាន ១:៥ ដល់ ចំពូក ២:២ ឬ អេសាយ ៥៣:៤-១១) ។
- ការច្រៀងចំរៀងអំពីការលន់តួសារភាព និងការជឿជាក់ថាខ្លួនបានព្រះជាម្ចាស់លើកលែងទោសអំពើបាបដោយបញ្ជាក់ពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ។
- ការអធិស្ឋានលន់តួសារភាពទូទៅទាំងអស់គ្នា ដែលអ្នកដឹកនាំអធិស្ឋាននាំមុខ ដូចជា :

«ឱព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ ! យើងខ្ញុំបានធ្វើបាបទាស់នឹងព្រះអង្គ និងទាស់នឹងមនុស្សឯទៀត ដោយគំនិត ពាក្យសំដី និងការប្រព្រឹត្តរបស់យើងខ្ញុំ ។ លើសពីនេះទៅទៀត យើងខ្ញុំបានធ្វើបាបទាស់នឹងព្រះអង្គ ដោយយើងខ្ញុំធ្វើការអាក្រក់ភ្លេចធ្វើការល្អ ព្រោះយើងខ្ញុំលង់ខ្ចៅ ទន់ខ្សោយ និងមានចេតនាធ្វើខុស ។ យើងខ្ញុំពិតជាសោកស្តាយខ្លាំងណាស់ ហើយសូមលន់តួសារភាពអំពើបាបទាំងអស់របស់យើងខ្ញុំ ។ សូមព្រះអង្គលើកលែងទោសអំពើបាបទាំងអស់របស់យើងខ្ញុំ

ដោយសារព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះអង្គ បានសុគតលើឈើឆ្កាងដើម្បីយើងខ្ញុំ ។ សូមព្រះអង្គជួយអោយយើងខ្ញុំអាចបំរើព្រះអង្គ ក្នុងជីវិតថ្មី ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះនាមរបស់ព្រះអង្គបានផង » ។

បើយើងថ្វាយបង្គំដោយមិនបានលន់តួសារភាពបាប នោះការថ្វាយបង្គំរបស់យើងមិនពេញលក្ខណៈទេ ។ បើមនុស្សមកថ្វាយបង្គំដោយមានអំពើបាបលាក់ទុកក្នុងចិត្ត និងក្នុងជីវិត នោះនឹងមានការរាំងស្ទះដល់ការថ្វាយបង្គំរបស់គេ ។ ការលន់តួសារភាព និងការកែប្រែចិត្តគំនិតបើកផ្លូវអោយមនុស្សអាចថ្វាយបង្គំ ដោយចិត្តបរិសុទ្ធបាន ។ គ្រូគង្វាលខ្លះ ដែលការពារខ្លួនពីលោកីយ៍ បានភ្លេចគិតថា ហ្វូងចៀមរបស់គាត់នៅក្នុងចំណោមអ្នកមិនជឿពេញមួយអាទិត្យ។ ហើយអាចនឹងធ្លាក់ចុះក្នុងសេចក្តីល្បួង ដែលគ្រូគង្វាលមិនសូវជួបប្រទះ ។ ជាពិសេស នៅក្នុងក្រុមជំនុំថ្មី សមាជិកជាច្រើនត្រូវមនសិការស្តីបន្ទោសខ្លាំង ពួកគេចាំបាច់ត្រូវលន់តួសារភាពកំហុសរបស់គេ និងស្តាប់ពាក្យសំដីពេញដោយសេចក្តីស្រឡាញ់ ដែលធ្វើអោយគេទុកចិត្តថា ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសណ្តោស និងលើកលែងទោសអោយគេ ។

ការបើកការថ្វាយបង្គំ

(ជាធម្មតាឈរ ។) បើជួបជុំគ្នានៅតាមផ្ទះណាមួយ ជាដំបូងត្រូវទូលសូមអោយព្រះជាម្ចាស់ធ្វើជាម្ចាស់លើផ្ទះនោះ និងក្រុមគ្រួសារដែលរស់នៅទីនោះ ព្រមទាំងលើអស់អ្នកដែលចូលរួមថ្វាយបង្គំ ។

- ខគម្ពីរសំរាប់បើកការថ្វាយបង្គំ ។
- ការអធិស្ឋានបើកការប្រជុំ ដើម្បីទូលសូមអោយវត្តមានរបស់ព្រះជាម្ចាស់ យាងមកគង់កណ្តាលចំណោមពួកគេ ។
- បទចំរៀងសំរាប់សរសើរតម្កើង ។

ការលន់តួសារភាពអំពើបាប និងការបញ្ជាក់ពីការដែលព្រះជាម្ចាស់បានលើកលែងទោសអំពើបាប

- ការអធិស្ឋានលន់តួសារភាព (ក្រុមជំនុំជាច្រើនចូលចិត្តបង្ហាញលក្ខណៈដាក់ខ្លួន ដូចជាលុតជង្គង់) ។
- ការបញ្ជាក់ថា ព្រះជាម្ចាស់បានលើកលែងទោសអំពើបាប។ (អរព្រះគុណព្រះអង្គចំពោះព្រះហឫទ័យប្រណីសន្តោសឥតព្រំដែនរបស់ព្រះអង្គ ព្រះអំណោយទានជាការអត់ទោស និង ការសង្គ្រោះដ៏នៅអស់កល្ប តាមរយៈព្រះយេស៊ូ) ។

យោបល់អំពីរបៀបថ្វាយបង្គំសំរាប់ក្រុមជំនុំតាមផ្ទះ

នេះជាគំរូពីរបៀបថ្វាយបង្គំសំរាប់ក្រុមជំនុំតាមផ្ទះ បើសិនជាអ្នកមិនទាន់មាន ។ ត្រូវផ្លាស់ប្តូររបៀបថ្វាយបង្គំ និងទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ ទើបជាការល្អ ។

នេះគ្រាន់តែជាយោបល់ខ្លះ ដូច្នេះ សូមយកសេចក្តីទាំងនេះទៅអនុវត្តតម្រូវទៅតាមស្ថានភាពជាក់ស្តែងរបស់អ្នក ដូចជាតំរិយាបថនៅពេលថ្វាយបង្គំ (ឈរ អង្គុយ លុតជង្គង់ ។ល។) ។

មុនចាប់ផ្តើម

- សូមទទួលភ្ញៀវ ហើយធ្វើអោយគេមានអារម្មណ៍ថា យើងទទួលគេដោយរាក់ទាក់ ។
- សូមខិតខំធ្វើអោយមនុស្សទាំងអស់ ដែលចូលរួមស្គាល់គ្នាទៅវិញទៅមក និងទុកឱកាសអោយគេចែកចាយអំពីគ្រួសាររបស់ពួកគេផ្ទាល់ ។
- សូមយកចិត្តទុកដាក់ចំពោះកុមារម្នាក់ៗ ។

ធ្វើអោយអ្នកដែលកែប្រែចិត្តគំនិត ដឹងជាក់ថាព្រះជាម្ចាស់បានលើកលែងទោសអោយចាបគេ ដោយ :

- ច្រៀងបទសរសើរតម្កើងអំពីការអត់ទោសរបស់ព្រះជាម្ចាស់ ឬ
- អធិស្ឋានអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ឬ
- អានបទគម្ពីរ ដូចជា :

អេសាយ ១:១៨	អេសាយ ៦:៦-៧
កិច្ចការ ១៣:៣៨-៣៩	អេភេសូ ១:៣-១៤
អេភេសូ ៤:៣២	ហេប្រឺ ៨:១២
ហេប្រឺ ៩:១២-១៤	

ជួយណែនាំមនុស្សទាំងអស់
អោយសរសើរតម្កើងព្រះជាម្ចាស់អស់ពីចិត្ត

នៅពេលដែលយើងសរសើរតម្កើងព្រះជាម្ចាស់ យើងត្រូវលែងគិតពីខ្លួនយើង ពីសេចក្តីត្រូវការរបស់យើង និងពីមនុស្សដែលនៅជុំវិញយើង ។ យើងគិតតែពីព្រះជាម្ចាស់ ដោយសរសើរតម្កើងព្រះអង្គអំពីចរិតលក្ខណៈរបស់ព្រះអង្គ និងអំពីកិច្ចការដ៏អស្ចារ្យដែលព្រះអង្គបានធ្វើ ។ មិនត្រូវបង្ខំមនុស្សអោយថ្វាយបង្គំ តាមរបៀបរបស់យើងទេ គឺត្រូវទុកអោយពួកគេថ្វាយបង្គំតាមរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំអោយពួកគេធ្វើ ។ ត្រូវរក្សាភាពសមរម្យ និងមានសណ្តាប់ធ្នាប់ថែមទៀតផង (១ កូរិនថូស ១៤:៤០) ។

បើត្រូវការជំនួយបន្ថែមអំពីចំរៀងថ្វាយបង្គំ សូមមើល :

កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល «ច្រៀងចំរៀងថ្វាយព្រះអម្ចាស់ »លេខ ៣១ ។

គ្រួសារប្រាប់គ្នាទៅវិញទៅមក ស្វាគមន៍ភ្ញៀវ និងចំណាយពេលជាមួយកុមារដែរ ។

អ្នកមិនចាំបាច់ត្រូវរៀបចំកម្មវិធីពិសេសៗ សំរាប់ប្រកបគ្នាគ្រប់ពេលនោះទេ ។ ប៉ុន្តែ អ្នកត្រូវរៀបចំសកម្មភាពពិសេសអ្វីមួយ ឬចំណីអាហារ ឬកម្មវិធីពិសេសមួយយូរៗម្តង ដើម្បីបង្កើតអោយមានទំនាក់ទំនងល្អក្នុងក្រុមជំនុំ ។ ការសំខាន់ គឺត្រូវមានពេលសំរាប់ជួបជុំគ្នាយ៉ាងជិតស្និទ្ធអោយបានទៀងទាត់យូរៗម្តង ក្រោយកម្មវិធីថ្វាយបង្គំ ប៉ុន្តែ មិនត្រូវអោយសកម្មភាពទាំងនេះ ជំនួសការសួរសុខទុក្ខគ្នាធម្មតាទេ ។

បើសិនជាអ្នកឃើញអ្នកណាម្នាក់ដែលអៀនច្រើន ឬ ឈរនៅម្នាក់ឯង សូមជួយណែនាំអោយអ្នកនោះជួបជាមួយអ្នកឯទៀត ដែលនឹងនិយាយលេងជាមួយគេ ។

សូមទុកពេលឱ្យភ្ញៀវនិយាយអំពីខ្លួនគេផ្ទាល់ ពីគ្រួសារ ការងាររបស់ពួកគេ មូលហេតុដែលនាំឱ្យពួកគេមកព្រះវិហារ ឬផែនការរបស់ពួកគេ ។ សូមស្តាប់ពួកគេដោយចិត្តស្មោះត្រង់ ។ ត្រូវបង្រៀនក្រុមជំនុំអោយចេះទទួលភ្ញៀវដោយសេចក្តីស្រឡាញ់ ការគោរព និងការរាប់អានគេទុកជាមិត្ត ។

© Project WorldReach © SEAN

ការបង្កើតសាវ័ក ជាការដឹកនាំអ្នកដទៃឱ្យចេះស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត ស្តាប់បង្គាប់ព្រះជាម្ចាស់ និងធ្វើពលីកម្មដើម្បីព្រះជាម្ចាស់ ។

អ្នកបង្កើតសាវ័កត្រូវជួបជាមួយសាវ័កជាអ្នកជឿថ្មី ដែលគេត្រូវជួយ ដោយទៀងទាត់ ដើម្បីណែនាំជំរុញអោយអ្នកនោះរីកចំរើនពេលដែលអ្នកនោះប្រតិបត្តិតាមព្រះគ្រីស្ត ហើយចូលរួមបំពេញមុខងារបំរើ ។

តើក្នុងក្រុមអ្នក អ្នកណាអាចបំពេញមុខងារជាអ្នកបង្កើតសាវ័ក ? សូមសរសេរឈ្មោះរបស់គេ និងអ្នកដែលគេត្រូវបង្រៀន ។

_____

_____

_____

ការប្រកបគ្នា

ពេលប្រកបគ្នា ជាពេលសំរាប់ជជែកលេងជាមួយគ្នានៅមុន ឬក្រោយការថ្វាយបង្គំ ។ គឺជាពេលសំរាប់អោយពួកអ្នកចូលរួមស្គាល់គ្នាទៅវិញទៅមក ចែកចាយអំពីបទពិសោធន៍ ឬដំណឹងអំពី

ការធ្វើទីបន្ទាល់

ផ្នែកសំខាន់នៃការថ្វាយបង្គំជាក្រុម គឺប្រកាសពីជំនឿរបស់យើងលើព្រះជាម្ចាស់ និងចែកចាយទីបន្ទាល់ពីការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងចំណោមយើង ។ យើងអាចធ្វើកិច្ចការនេះ តាមរបៀបច្រើនយ៉ាង :

- ដោយច្រៀងបទសរសើរតម្កើង ដែលប្រកាសពីជំនឿរបស់យើង

  ឬ

- អញ្ជើញសមាជិកអោយចែកចាយប្រាប់ពីកិច្ចការ ដែលព្រះ-ជាម្ចាស់បានធ្វើ នៅក្នុងជីវិតរបស់គេ នៅក្នុងសប្តាហ៍នោះ

  ឬ

- និយាយរួមគ្នាពីគោលជំនឿរបស់ក្រុមជំនុំដូចជា :

គោលជំនឿរបស់ពួកសាវ័ក

ខ្ញុំជឿលើព្រះជាម្ចាស់ជាព្រះបិតាដ៏ធំខ្ពស់បំផុត ដែលបង្កើតស្ថានបរមសុខ និងផែនដី ។ ខ្ញុំជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តដែលជា

ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូបានប្រសូតពីស្ត្រីព្រហ្មចារីយ៍ ឈ្មោះនាងម៉ារី ដោយសារឫទ្ធានុភាពរបស់ព្រះ-វិញ្ញាណដ៏វិសុទ្ធ ។ ព្រះយេស៊ូបានរងទុក្ខវេទនានៅក្នុងសម័យកាល ដែលលោកពីឡាត់ដឹកនាំរដ្ឋអំណាច ។ ព្រះអង្គបានសុគតនៅលើឈើឆ្កាង និងត្រូវគេបញ្ចុះក្នុងផ្នូរ ។ ព្រះអង្គបានយាងចុះទៅស្ថាននរក ហើយនៅថ្ងៃទីបីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ។ ព្រះអង្គបានយាងឡើងទៅស្ថានបរមសុខ ហើយគង់នៅខាងស្តាំព្រះជាម្ចាស់ជាព្រះបិតាដ៏ខ្ពស់បំផុត ។ ព្រះអង្គនឹងយាងពីស្ថានបរមសុខមកផែនដី ដើម្បីជំនុំជំរះមនុស្សរស់ និងមនុស្សស្លាប់ ។ ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ និងកិច្ចការរបស់ព្រះអង្គ ។ ខ្ញុំទទួលស្គាល់ក្រុមជំនុំសកលលោក ការរួមចិត្តគំនិតគ្នារវាងពួកអ្នកជឿ ការលើកលែងទោសអំពើបាប ការរស់ឡើងវិញរបស់អ្នកជឿ និងជីវិតអស់កល្បជានិច្ច ។ អាម៉ែន ។

រៀបចំពេលវេលាសំរាប់ការបង្កើតសាវ័ក និងការប្រកបគ្នា

ការបង្កើតសាវ័ក

ត្រូវរៀបចំពេលវេលាសំរាប់ការបង្កើតសាវ័ក ។ អាចធ្វើនៅមុន ឬក្រោយពេលចប់កម្មវិធីថ្វាយបង្គំ ឬ នៅក្នុងសប្តាហ៍តាមផ្ទះ ។

ពេលដែលអ្នកជឿថ្មីយល់ពីជំរៅនៃជំនឿលើព្រះគ្រីស្ត ពួកគេត្រូវការជំនួយ ដើម្បីឱ្យអាចប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងជីវិតគេ និងចាប់ផ្តើមធ្វើកិច្ចការបំរើថ្វាយព្រះអម្ចាស់យេស៊ូបាន ។

អ្នកត្រូវចាត់អោយ « អ្នកបង្កើតសាវ័ក » ម្នាក់ ជួយអ្នកជឿថ្មីម្នាក់ អោយអាចចាប់ផ្តើមប្រតិបត្តិតាមសេចក្តីបង្គាប់ដ៏សំខាន់របស់ព្រះយេស៊ូ ដូចជា : ធ្វើពិធីជ្រមុជទឹក ស្រឡាញ់អ្នកដទៃ ជួយអ្នកដទៃ អត់ទោសអោយអ្នកដទៃ ចូលរួមធ្វើពិធីកាច់នំប៉័ង ថ្វាយអ្វីៗទៅព្រះអម្ចាស់ អោយដល់មនុស្សឯទៀត អធិស្ឋានទៅព្រះជាម្ចាស់ និងផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូ ។ អ្នកបង្កើតសាវ័កក៏ត្រូវជួយអ្នកជឿថ្មីនោះ ឱ្យដឹងពីអំណោយទានខាងព្រលឹងវិញ្ញាណរបស់ខ្លួន និងពីរបៀបយកអំណោយទាននោះទៅប្រើដើម្បីបំរើព្រះជាម្ចាស់ផងដែរ ។

នេះជាខគម្ពីរផ្សេងៗ ដែលរៀបរាប់អំពីពិធីកាច់នំប៉័ង

- ម៉ាថាយ ២៦:២៦ សំរាប់នំប៉័ង និង ខ ២៦:២៧-២៨ សំរាប់ទឹកទំពាំងបាយជូរ ។
- លូកា ២២:១៩ សំរាប់នំប៉័ង និង ២២:២០ សំរាប់ទឹកទំពាំងបាយជូរ ។
- ម៉ាកុស ១៤:២២ សំរាប់នំប៉័ង និង ១៤:២៣-២៤ សំរាប់ទឹកទំពាំងបាយជូរ ។
- ១ កូរិនថូស ១១:២៣-២៤ សំរាប់នំប៉័ង និង ១១:២៥ សំរាប់ទឹកទំពាំងបាយជូរ ។

ក្រុមជំនុំទាំងឡាយមានទំលាប់ធ្វើពិធីកាច់នំប៉័ងផ្សេងៗពីគ្នា ។ ពួកសាវ័កបានប្រើ «ស្រាទំពាំងបាយជូរ» តែក្រុមជំនុំខ្លះនិយមប្រើទឹកទំពាំងបាយជូរ ឬភេសជ្ជៈផ្សេងៗ ដែលគ្មានជាតិស្រវឹង ។

ការអធិស្ឋាន

នៅពេលថ្វាយបង្គំ យើងអធិស្ឋានច្រើនជាងធ្វើអ្វីៗផ្សេងទៀត គឺយើងអធិស្ឋានដោយពាក្យសំដី គំនិត ឬចំរៀង ។ យើងអធិស្ឋានពេលបើកកម្មវិធី ពេលសរសើរតម្កើង ពេលលន់តួសារភាពអំពើបាប ពេលធ្វើពិធីកាច់នំប៉័ង និងពេលទូលសុំព្រះពរដើម្បីបញ្ចប់។

យើងត្រូវទុកពេលអធិស្ឋានទូលអង្វរ ជាពិសេស ទុកឱ្យសមាជិកមានឱកាសអធិស្ឋានអោយគ្នាទៅវិញទៅមក និងអធិស្ឋានសំរាប់កិច្ចការរបស់ព្រះអម្ចាស់ ។ នៅក្នុងក្រុមតូច សូមជួយអោយអ្នកដែលចូលរួមអាចអធិស្ឋានបាន រួមទាំងកុមារផងដែរ ។ ជួនកាលអ្នកខ្លះពេញចិត្តអធិស្ឋានក្នុងចិត្តស្ងៀមស្ងាត់ ចូរទុកឱ្យគេអធិស្ឋានរបៀបនោះចុះ ។

បើសិនជាមានក្រុមតូច ត្រូវអធិស្ឋានសំរាប់សមាជិកនិមួយៗដែលបានមកចូលរួម ។ កុំអនុញ្ញាតឱ្យមនុស្សចែកចាយទីបន្ទាល់ពីសេចក្តីត្រូវការរបស់ខ្លួនយូរពេក ក្រែងលោការថ្វាយបង្គំនៅក្នុងក្រុមជំនុំតាមផ្ទះ បែកចេញពីគោលដៅរបស់ខ្លួន បែរទៅជាការរអ៊ូរទាំអំពីបញ្ហាផ្ទាល់ខ្លួនវិញ ។

ការដាក់ក្រាក់ដង្វាយ

ការថ្វាយដង្វាយ គឺជាផ្នែកមួយនៃការថ្វាយបង្គំព្រះជាម្ចាស់របស់យើង ។

នៅក្នុងក្រុមតូច បើការដែលហុចថង់ដង្វាយពីមួយទៅមួយ ជាការពិបាក នោះយើងអាចដាក់ប្រអប់សំរាប់ដាក់ដង្វាយនៅក្បែរមាត់ច្រកទ្វារចូល ដើម្បីឱ្យមនុស្សអាចដាក់ដង្វាយដប់ភាគរយ និងដង្វាយស្ម័គ្រចិត្តរបស់គេ នៅពេលដែលអ្នកចូលរួមដើរចូលមក ឬ ចេញទៅ ។

ដើម្បីអោយកាន់តែយល់ច្បាស់អំពីដង្វាយដប់ភាគរយ និងការចាត់ចែងថវិកា សូមមើលក្លូនសៀវភៅ : «អ្នកធ្វើអំណោយដោយចិត្តអំណរ » ។

នៅក្នុងក្រុមជំនុំថ្មីតាមផ្ទះ ការដែលប្រសើរបំផុត គឺចាប់ផ្តើមថ្វាយដង្វាយដប់ភាគរយ និងដង្វាយស្ម័គ្រចិត្តតាំងពីដំបូងភ្លាម ។ បើមនុស្សមិនថ្វាយដង្វាយ គេមិនបានធ្វើតាមសេចក្តីបង្គាប់ជ័សំខាន់របស់ព្រះគ្រីស្តទេ ។ មួយវិញទៀត ការថ្វាយបង្គំ និងការបង្កើតសាវ័ករបស់ពួកគេក៏មិនបានសំរេចពេញលេញដែរ ។

ក្រុមជំនុំថ្មី អាចមានសមាជិកតិច ។ ការធ្វើពិធីកាច់នំបុ័ងជួយឱ្យគេដឹងថា គេជាផ្នែកនៃព្រះកាយរបស់ព្រះគ្រីស្ត និងជាក្រុមជំនុំពិតប្រាកដ ដែលមានការថ្វាយបង្គំពិត ។

ពេលបានទទួលនំបុ័ង ត្រូវអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះគ្រីស្តស្ម័គ្រព្រះហឫទ័យរងទុក្ខវេទនាលើឈើឆ្កាង ដើម្បីសង្គ្រោះយើងរាល់គ្នា ។ បន្ទាប់មក សូមចែកចាយពន្យល់ឬក៏អានខគម្ពីរស្តីពីអត្ថន័យនំបុ័ង ដែលជានិមិត្តរូប ។ សូមនិយាយតាមព្រះបន្ទូលព្រះយេស៊ូថា÷ *«នេះជាព្រះកាយខ្ញុំ...»* ។

ពេលបានទទួលទឹកទំពាំងបាយជូរ ត្រូវអរព្រះគុណព្រះជាម្ចាស់ដោយសារព្រះគ្រីស្តស្ម័គ្រព្រះហឫទ័យ បង្ហូរព្រះលោហិតរបស់ព្រះអង្គលើឈើឆ្កាងដែលជាសម្ពន្ធមេត្រីថ្មី ដើម្បីដកបាបរបស់យើងរាល់គ្នាចេញ ។ បន្ទាប់មក ចែកចាយពន្យល់ ឬក៏អានខគម្ពីរអំពីអត្ថន័យទឹកទំពាំងបាយជូរ ដែលជានិមិត្តរូប ។ សូមនិយាយតាមព្រះបន្ទូលព្រះយេស៊ូថា÷*«នេះជាឈាមខ្ញុំ...»* ។

ធ្វើពិធីកាច់នំប៉័ង

នៅក្នុងប្រវត្តិរបស់ក្រុមជំនុំទាំងមូល ពិធីកាច់នំប៉័ងជាកិច្ចការសំខាន់នៃពិធីថ្វាយបង្គំរបស់ពួកគ្រីស្តជន ។

ក្រុមជំនុំតាមផ្ទះថ្មីៗខ្លះ មិនបានទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធ ប្រើអាថិកំបាំងដ៏ជ្រាលជ្រៅ និងរឿងរ៉ាវអំពីពិធីកាច់នំប៉័ង ដើម្បីជំរុញអោយមនុស្សថ្វាយបង្គំពិត និងដោយកិត្តិយសទេ ។ ពួកគេធ្វើពិធីកាច់នុំប៉័ង ដូចជាពិធីសាសនាមួយ ។ ប៉ុន្តែ ពិធីកាច់នំប៉័ងជាឱកាសដ៏អស្ចារ្យមួយ ដើម្បីឱ្យយើងថ្វាយបង្គំ និងទទួលព្រះពរពីព្រះជាម្ចាស់ ។ ពិធីកាច់នំប៉័ងនាំអោយសមាជិកក្រុមគួចតាមផ្ទះថ្វាយបង្គំដោយសេចក្តីពិត ។

ការធ្វើពិធីកាច់នំប៉័ង ជួយអោយអ្នកជឿដឹងថា ពួកគេជាសមាជិកគ្រួសាររបស់ព្រះជាម្ចាស់ និងថាការថ្វាយបង្គំ ជាការសំខាន់ ។ ត្រូវខិតខំប្រតិបត្តិតាមសេចក្តីបង្គាប់ដ៏សំខាន់នេះរបស់ព្រះជាម្ចាស់យ៉ាងឆាប់តាមដែលអាចធ្វើបាន ស្របទៅតាមទំលាប់របស់ក្រុមជំនុំ ឬនិកាយរបស់អ្នក ។

សិក្សា និង អនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់

សកម្មភាពទាំងអស់នៅក្នុងការប្រជុំថ្វាយបង្គំ សុទ្ធតែមានមូលដ្ឋានក្នុងព្រះគម្ពីរ ដូចជាការសិក្សាព្រះបន្ទូល ការនាំសមាជិកថ្វាយបង្គំ ការនាំសមាជិកច្រៀងសរសើរតម្កើងព្រះជាម្ចាស់ ការបញ្ជាក់ថាព្រះជាម្ចាស់បានអត់ទោស និង ការធ្វើពិធីកាច់នំប៉័ង ។

នៅក្នុងក្រុមតូច មិនគួរឈរអធិប្បាយទេ ។ បើសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរបៀប ដែលនាំអោយទាំងអស់គ្នាអាចចូលរួមបាន ដូចជានិទានរឿងនៅក្នុងព្រះគម្ពីរ សួរសំណួរ និងនិយាយលើកទឹកចិត្តខ្លី។ ឬពន្យល់ខ្លី។ ជាការប្រសើរជាង ។

អានវគ្គគម្ពីរមួយ ហើយសួរសំណួរ ។ ក្រុមទាំងមូលអាចអានវគ្គគម្ពីរទាំងមូលជាមួយគ្នា ឬអានម្នាក់មួយខក៏បានដែរ ។ បើមានអ្នកខ្លះមិនចេះអាន គេអាចថាតាមអ្នកដែលអានមួយឃ្លាម្តងៗ ។

សួរសំណួរដែលជួយមនុស្សឱ្យយល់ពីសេចក្តីពិតសំខាន់ៗនៅក្នុងវគ្គគម្ពីរនោះ ។ សួរសំណួរស្រួលៗទៅកុមារ ។ ចូរជួយអ្នកដែលចូលរួមសិក្សាទាំងអស់អោយអាចចូលរួមក្នុងការពិភាក្សាបាន ។ (ប៉ុន្តែ មិនត្រូវបង្ខំអ្នកអៀន ឬ អ្នកមកថ្មីឱ្យនិយាយទេ បើសិនជាគេមិនទាន់អាចនិយាយបាន) ។ ជួយគេទាំងអស់គ្នាឱ្យអាចធ្វើ

ផែនការ ដើម្បីអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្នុងជីវិតរស់នៅរបស់ពួកគេ ។

វិធីដែលងាយស្រួលសំរាប់ការសិក្សាព្រះគម្ពីរជាក្រុម

ពន្យល់ប្រាប់អំពីប្រធានបទរបស់វគ្គព្រះគម្ពីរ អានវគ្គព្រះគម្ពីរនោះ និងសួរសំណួរខាងក្រោមនេះ ដើម្បីជួយសមាជិកក្រុមជំនុំឱ្យយល់ពីខព្រះគម្ពីរ និងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

- «តើវគ្គគម្ពីរនេះនិយាយអំពីអ្វី ? » ។

  មុនពេលសិក្សាជាមួយគ្នា សូមគូសចំណាំខគម្ពីរ ដែលទាក់ទងនឹងចំណុចសំខាន់បំផុតរបស់ប្រធានបទ ។

  បើចាំបាច់ សូមនិយាយថា÷ «នៅក្នុងខ៣ តើអ្នកបានឃើញសេចក្តីសំខាន់អ្វីខ្លះអំពីប្រធានបទ ?»។ ការធ្វើដូច្នេះសមល្មម សំរាប់ជួយមនុស្សឱ្យអាចចូលរួមសិក្សាបាន ។

- «នៅក្នុងវគ្គនេះ តើមានសេចក្តីបង្គាប់ ដែលយើងត្រូវប្រតិបត្តិតាមដែរឬទេ ? បើមាន គឺអ្វី ?» ។

- «តើមានគំរូដែលយើងត្រូវប្រតិបត្តិតាមដែរឬទេ ? បើមាន គឺអ្វី ?» ។

តុលាការដែលចោទប្រកាន់ព្រះអម្ចាស់យេស៊ូ

ម៉ាកុស ១៤:៤៣-៧២

ការឆ្កាងព្រះយេស៊ូ

ម៉ាកុស ១៥

ការមានព្រះជន្មរស់ឡើងវិញ

លូកា ២៤

ការយាងឡើងទៅស្ថានបរមសុខ

យ៉ូហាន ១៤

កិច្ចការ ១:១-១១

© Project WorldReach © SEAN

ឫជាចារ្យដ៏ធំខ្ពស់បំផុតរបស់យើង

លេវីវិន័យ ៨:១២-១៣, ៩:៨-១៥, ៩:២២-២៤

លេវីវិន័យ ១០:១-៧, ១៦:១-៣, ១៥-១៩

ហេប្រឺ ៩:១១-១៤

ពស់លង្ហិន

ជំរឿនប្រជាជន ២១:៤-៩

យ៉ូហាន ៣:១-១៦

រង្វាន់ និង ទោសសំរាប់គ្រីស្តជន

១ កូរិនថូស ៣:១១-១៥

វិវរណៈ ៧:៩-១៧

(សូមមើលឧទាហរណ៍ក្នុងសម្ពន្ធមេត្រីចាស់ អំពីបល្ល័ង្ករបស់ព្រះគ្រីស្ត នៅក្នុងជំរឿនប្រជាជន ៣១:១-១២ និង ២១-២៤) ។

- «តើមានការដែលយើងគួរចៀសវាងដែរឬទេ ? បើមាន គឺអ្វី ? » ។
- «តើមានសេចក្តីសន្យាដែលយើងត្រូវប្រកាសដែរឬទេ ? បើមាន គឺអ្វី ?» ។
- តើយើងត្រូវអនុវត្តតាមសេចក្តីដែលយើងបានសិក្សារួចហើយដោយរបៀបណា ?

វគ្គគម្ពីរសំរាប់ការសិក្សាព្រះគម្ពីរជាក្រុម

វគ្គគម្ពីរបន្តបន្ទាប់នេះ ជាឧទាហរណ៍អំពីវគ្គគម្ពីរដែលសមស្របសំរាប់ការបង្រៀនរបៀបនេះ ។ (ប្រសិនបើវគ្គគម្ពីរខ្លះ វែងពេកសំរាប់ក្រុមរបស់អ្នក អ្នកដឹកនាំត្រូវសិក្សាវគ្គគម្ពីរនោះជាមុនសិនដើម្បីជ្រើសយកផ្នែកដែលជាគន្លឹះសំរាប់អាន) ។

ការបង្កើត

កំណើតពិភពលោក ១:១ ដល់ ២:៤

អេភេសូ ២:៦-១០

វិវរណៈ ២១:១-៥

© Project WorldReach © SEAN

អំពើបាប

កំណើតពិភពលោក ៣:១-១៩

រ៉ូម ៥:១២-១៩

វិវរណៈ ២២:១-១៥

ការជំនុំជំរះ (ការកាត់ទោស)

កំណើតពិភពលោក ៦:៥-៧, ៧:៧-១៣, ៧:១៧-២២,

៨:១-៥, ៨:១៨-២០

ម៉ាថាយ ២៤:៣៧-៤១

វិវរណៈ ២០:១១-១៥

ជំនឿរបស់លោកអ្រាហាំ

កំណើតពិភពលោក ១២:១-៣, ១៧:១-៨

កាឡាទី ៣:៦-៩, ៣:១៣-១៧

ព្រះជាម្ចាស់សាកល្បងលោកអ្រាហាំ

កំណើតពិភពលោក ២២:១-១៨

ម៉ាថាយ ៤:១-១១

១ ពេត្រុស ១:៦-៩

ព្រះយេស៊ូជាកូនកំលោះរបស់ក្រុមជំនុំ

អេភេសូ ៥:២២-៣៣

វិវរណៈ ២១:១-៤

ព្រះជាម្ចាស់គង់នៅអស់កល្ប

សេរីភាព ៣:១-១៧

យ៉ូហាន ៨:៤៨-៥៩

យ៉ូហាន ១១:២១-២៧

ការសង្គ្រោះ

សេរីភាព ១១:១, ១២:១-៨, ១៣:២១-២៤, ២៩-៣៣

សេរីភាព ១៤:៥-៦, ១៩-២៧, ១៥:១-៥

យ៉ូហាន ១:៣៥-៣៦

ក្រិត្យវិន័យរបស់សម្ពន្ធមេត្រីចាស់

សេរីភាព ១៩:១៦, ២០:២០

រ៉ូម ៧:១-៦

រ៉ូម ៨:១-៤

© Project WorldReach © SEAN